# តាគង់ និងពិធីឡើងមាឃនៅវត្តខ្នាត

ពិធីឡើងមាឃ ឬឡើងអ្នកតា ជាទំនៀមទម្លាប់ដែលតែងធ្វើនៅពេលការប្រមូលផលស្រូវចាប់រួចរាល់សព្វគ្រប់ទាំងស្រុង។ ពីដើមមក គេតែងធ្វើជាទៀងទាត់នៅថ្ងៃ៣កើតខែមាឃ។ នៅវត្តខ្នាតនេះក៏នៅប្រព្រឹត្តតាមទម្លាប់ពោលគឺ ថ្ងៃ៣កើតខែមាឃជាទៀងទាត់ដែរ។ សូមបញ្ជាក់ថា ភូមិខ្លះអាចធ្វើនៅថ្ងៃផ្សេងៗគ្នា ត្បិតអាស្រ័យលើការមូលមតិគ្នារបស់អ្នកភូមិផ្ទាល់ ទោះយ៉ាងនេះក្ដីក៏ច្រើនតែរើសក្នុងខែមាឃ។ ជួនកាលទៀតក៏អាស្រ័យលើស្ថានភាពជាក់ស្ដែងរបស់ទីតាំងដែលត្រូវកិច្ចពិធីនោះដែរ។[១] គិតមកត្រឹមពេលថ្មីៗនេះ ប្រធានបទអំពីឡើងមាឃមានការសិក្សាច្រើនគួរសមដែរ។[២] រីឯអត្ថបទនេះខ្ញុំលើកយកករណីពិធីឡើងមាឃនៅវត្តខ្នាតដែលខ្ញុំបានសង្កេតនៅឆ្នាំ២០២៣មកបង្ហាញជូន។

វត្តខ្នាតស្ថិតនៅភូមិខ្នាត ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ជាប់ផ្លូវជាតិលេខ៦ ទិសនិរតីបារាយណ៍ទឹកថ្លា។ វត្តនេះស្ថិតនៅលើបុរាណដ្ឋានចាស់ដែលមានសំណង់ប្រាសាទសាងសង់ក្នុងសម័យមុនអង្គរ និងសាងសង់បន្ថែមក្នុងសម័យអង្គរ។ ទីតាំងប្រាសាទស្ថិតនៅក្រោមព្រះវិហារសព្វថ្ងៃនេះឯង។ នៅក្នុងដំណើរធ្វើបញ្ជីប្រាសាទខ្មែរដំបូងៗ អ្នកស្រាវជ្រាវបានកត់សម្គាល់ថា វត្តមានប្រាសាទឥដ្ឋដែលបាក់បែកខ្លាំង។ ទីនោះគេបានប្រទះសិលាចារឹក (K.259) ព្រមទាំងប្រែសេចក្ដីសង្ខេបខ្លះៗផង។[៣] ថ្មភក់ និងថ្មបាយក្រៀមជាដើមត្រូវព្រះសង្ឃយកប្រើឡើងវិញសម្រាប់ការសាងសង់ព្រះវិហារ។[៤] តាមការកំណាយស្រាវជ្រាវបានរកឃើញតឹកតាងនៃដំណាក់កាលសំខាន់ៗក្នុងបរិវេណប្រាសាទ។[៥] ចំណែកសិលាចារឹកនោះ

---

[១] ឆាន់ សុភីនី et al. ២០២១។

[២] អាំង ជូលាន ២០១៤-២០២៣ ឆាន់ សុភីនី ,et al. ២០២១ ,ហៀន សុវណ្ណមរកត ២០២៣។

[៣] Aymonier 1901: 393-395។

[៤] Lajonquière 1911: 281។

[៥] Pottier et al., 2001។

អត្ថបទដោយ៖ អ៊ូ គង្គា

និយាយអំពីដង្វាយចំពោះព្រះនារាយណ៍ព្រះនាម«ត្រីលោកនាថ» ដែលតម្កល់ក្នុងប្រាសាទ។[៦] នៅខាងកើតព្រះវិហារមានសល់ស្រះតូចមួយទំហំប្រហែល៥ម៉ែត្រX៥ម៉ែត្រ ដែលទំនងជាស្រះសល់ពីសម័យបុរាណមកដែរ។ ថ្មភក់ដែលគទុកខាងក្រោយខ្ទមអ្នកតាយកចេញពីស្រះនេះក្នុងពេលដែលព្រះសង្ឃមានបំណងរៀបខឿនស៊ីម៉ងត៍ជុំវិញស្រះ។[៧] ដើមឡើយស្រះនេះ គឺជាប្រភពទឹកយ៉ាងសំខាន់សម្រាប់ប្រើប្រាស់ក្នុងភូមិ មុនគ្រួសារនីមួយៗមានអណ្តូងទឹកប្រើតាមផ្ទះ។

ក្នុងឆ្នាំ២០២៣ គេរៀបចំពិធីនៅខាងមុខខ្ទមអ្នកតាក្រោមដើមពោធិ៍ ខាងកើតព្រះវិហារ។ តែមុនសម័យខ្មែរក្រហម ខ្ទមអ្នកតាស្ថិតនៅក្រោមដើមច័នត្រង់ទិសឦសានជាប់ខឿនព្រះវិហារតែម្តង (រូបលេខ១)។ លុះដល់ក្រោយចប់សម័យខ្មែរក្រហមបានបន្តិច ទើបគេមកធ្វើខ្ទមនៅលើទីតាំងបច្ចុប្បន្នជាប់នឹងទ្វារចេញចូលវត្តពីខាងកើត។

អ្នកតាក្នុងខ្ទមនេះ គឺតាគង់ ដែលជាអ្នកតាប្រចាំវត្ត និងប្រចាំភូមិខ្នាត។ សព្វថ្ងៃមានរូបសំណាកមនុស្សប្រុសឈរដែកាន់ត្រីសូរ ដែលជារូបថ្មីដែលគេទើបតែដាក់ចូលនៅឆ្នាំ២០២២។ តែមុននេះ គឺជារូបចម្លាក់ធ្វើពីស៊ីម៉ងត៍ អង្គុយដាក់ដៃលើភ្លៅ។ នៅដើមស.វទី២០ លោក Lajonquière បានកត់សម្គាល់នៅទីតាំងនេះថា បុរាណដ្ឋាននេះមានបដិមាធំមួយដែល«ចម្លង»ចេញពីបដិមាស្តេចគម្លង់នៅក្រុងអង្គរធំ (រូបលេខ២)។[៨] នៅឆ្នាំ១៩៣០ រេស៊ីដង់ខេត្តសៀមរាបបានយកបដិមានោះមកដាក់នៅជិតមាត់ស្ទឹងតាមផ្លូវជាតិលេខ៦ ក្នុងក្រុងសៀមរាបសព្វថ្ងៃ។[៩] អ្នកស្រុកចំណុះជើងវត្តខ្នាតនិយាយតៗគ្នាថា ចម្លាក់តាគង់ត្រូវគេ

---

[៦] Cœdès 1964: 50-57។ ឈ្មោះទេពនេះឯងដែលនាំឲ្យគេជឿថាវិវត្តមកជាដល់សព្វថ្ងៃ«ខ្នាត»។ ករណីយកឈ្មោះទេពរូបមកហៅឈ្មោះប្រាសាទ សូមអាន Pou 1991: 213។

[៧] ស្រះនេះមានរឿងព្រេងទាក់ទងនឹងស្តេចគម្លង់ ត្បិតអ្នកស្រុកជឿថា ទីនេះជាខ្នាចដែលស្តេចគម្លង់ចុះត្រាំថ្នាំ។

[៨] Lajonquière 1911: 281-282។

[៩] EFEO 1930: 583។

ដឹកតាមរទេះទៅដល់មុខរាជដំណាក់ក្រុងសៀមរាបក៏សម្រាកមួយយប់។ លុះព្រឹកឡើងក៏ត្រូវគេលួចកាត់ក្បាលយកទៅបាត់ ទើបគេក៏រក្សាទុកនៅទីនោះរហូតមក។ នៅសម័យខ្មែរក្រហម គេយកបដិមានេះទៅបោះចូលស្រះក្នុងវត្តដំណាក់។ ទើបនៅឆ្នាំ១៩៨៥ អភិរក្ស-ដ្ឋានអង្គរ និងអ្នកស្រុកសៀមរាបយកមកដាក់នៅទីតាំងខាងជើងព្រះរាជដំណាក់មកដល់បច្ចុប្បន្ន ដែលគេស្គាល់បដិមានេះជាទូទៅថា «យាយទេព» (រូបលេខ៣)។[១០]

ត្រឡប់ទៅមើលពិធីឡើងមាយវិញគឺថា ពិធីនេះធ្វើតែមួយរសៀលប៉ុណ្ណោះ។ នៅទីនេះប្ញីត្បិតតែឡើងមាយក្នុងបរិវេណវត្តក៏ដោយ តែយើងពុំទាន់ឃើញមានវត្តមាន ឬតួនាទីព្រះសង្ឃនៅក្នុងកិច្ចពិធីនោះទេ ខុសពីពិធីឡើងមាយតាមភូមិមួយចំនួនដែលមានតួនាទីព្រះសង្ឃក្នុងនោះដែរ ហើយច្រើនតែធ្វើនៅតាមសាលាបុណ្យក្នុងភូមិ។ នៅម៉ោង៣រសៀលអ្នកស្រុកមកជុំគ្នានៅខាងមុខខ្ទមអ្នកតា។ គ្រឿងរណ្តាប់មានដូចជា បាយសី ជមរូប បាយសម្ល នំបញ្ចុក មាន់ស្ងោ ក្បាលជ្រូក បង្អែម ផ្លែឈើ ទឹកក្រូច កាហ្វេ (រូបលេខ៤)។ល។

ក្នុងកម្មវិធីនេះមានបញ្ចូលរូបអ្នកតាឱ្យរាំលេងសប្បាយ និងដើម្បីឱ្យអ្នកស្រុកជួបអាស្រ័យនឹងអ្នកតាគង់។ នៅពេលអ្នកតាចូល រូបយកខោអាវពណ៌ក្រហមមកប្រើ និងយកកន្សែងក្រហមមកឈ្នួតក្បាលរាំរែកជាមួយភ្លេងពិណពាទ្យ (រូបលេខ៥-៦)។ នៅពេលរាំសប្បាយរួចរាល់ អ្នកតាប្រោះទឹកលើអ្នកចូលរួមឱ្យមានភាពត្រជាក់ត្រជុំក្នុងគ្រួសារ និងបញ្ចៀសជម្ងឺផ្សេងៗ។ កម្មវិធីបញ្ចប់នៅម៉ោង៥ល្ងាចនាថ្ងៃដដែលនោះ។

ជារួម តាមការសង្កេតជាទូទៅ ប្ញីត្បិតតែរូបចម្លាក់តាគង់ត្រូវគេយកចេញពីវត្តតាំងពីយូរមកហើយក្តី ក៏ប៉ុន្តែអ្នកតាគង់នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចពិធីទាក់ទងនឹងកសិកម្មនៅខែប្រមូលផលស្រូវចប់រួចរាល់ជាស្ថាពរនេះ។ម្យ៉ាងទៀតពិធីធ្វើនៅក្នុងទីធ្លាវត្តមែនក៏នៅមិនទាន់ទទួលឥទ្ធិពលពុទ្ធសាសនាខ្លាំងក្លានោះឡើយ បើធៀបនឹងតំបន់ដទៃ។ ពិធីនេះសំខាន់សម្រាប់អ្នកភូមិពឹងអាស្រ័យ ពិសេសរឿងស្រូវដែលស្ទើតែទាំងស្រុងនៃអ្នកភូមិទីនេះជាអ្នកធ្វើស្រែ។

---

[១០] Hang 2004។

អត្ថបទដោយ៖ អ៊ូ គង្គា

## ឯកសារពិគ្រោះ

អាំង ជូលាន, ២០១២-២០១៣, «៣កើត មាយធំ» កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ, លេខ៨, ភ្នំពេញ, ទំ.៤៣-៤៨

ធាន់ សុភីនី, សោ ចន្ទា, តូច សុភ:, ជា សំបូរ, អាន សីមា និង អ៊ូ គង្គា, ២០២១, «កិច្ចពិធីនៅចុងវដ្តស្រូវ៖ ករណីឡើងមាយនៅភូមិបង្កោង» ព្រះនគរ, លេខ១៣, អាជ្ញាធរជាតិអប្សរា (បេញផ្សាយខាងមុខ)

ហៀន សុវណ្ណមរកត, ២០២៣, «ឡើងមាយ»តាមទំនៀមអ្នកស្រុកអង្គរ, ក្នុង https://ams.com.kh/khmercivilization/detail/26231

Aymonier, Etienne, 1901, *Le Cambodge III: Le Groupe d'Angkor et l'Histoire*, Paris

Cœdès, Goerges, 1964, *Inscription du Cambodge*, vol.7, Paris

EFEO, 1930, "Chronique: Cambodge", *BEFEO.30*, p. 487-647

Hang, Chansophea, 2004, "Stec Gamlan and Yay Deb: Worshiping Kings and Queens in Cambodia Today" *History, Buddishm, and New Religious Movements in Cambodia*. John Marston and Elizabeth Guthrie (eds). Honolulu: University of Hawai'i Press. p.113-131

Lajonquière, Lunet de, 1911, *Inventaire Descriptif des Monuments du Cambodge. Tome III*, Paris.

Pottier, Christophe, Alexandrine Guerin, Than Heng, Sokrithy Im, Tchan Koy, Eric Llopis, 2001, *Mission Archéologique FrancoKhmère sur l'Aménagement du Territoire Angkorien (MAFKATA): Rapport sur la Campagne de Fouilles 2000*, APSARA, MAE, EFEO

Pou, Saveros, 1991, "Les Noms des Monuments Khmers", *BEFEO.78*, p. 203-227



រូបលេខ១ ព្រះវិហារវត្តខ្នាត និងដើមច័ននៅទិសឦសាន



រូបលេខ២ អ្នកតាគង់នៅវត្តខ្នាត (EFEO_CAM00624)



រូបលេខ៣ យាយទេព

អត្ថបទដោយ៖ អ៊ូ គង្គា



រូបលេខ២៤ រណ្ដាប់



រូបលេខ២៥



រូបលេខ២៦

អត្ថបទដោយ៖ អ៊ូ គង្គា